សួស្តី! នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការទៅញ៉ាំសាច់គោឡើងភ្នំ។
អញ្ចឹងសាច់គោឡើងភ្នំ អញ្ចឹងជាទូទៅការញ៉ាំសាច់គោឡើងភ្នំគឺយើងញ៉ាំនៅពេលល្ងាច។
ហើយសាច់គោឡើងភ្នំគឺយើងអត់ មិនមែនជាអាហារពេលល្ងាច ឬក៏អាហារពេលថ្ងៃត្រង់នោះទេ។
វាគឺជាអាហារញ៉ាំកម្សាន្តមួយ[ដែល] នៅពេលដែលយើងជួបជុំមិត្តភក្តិ
ឬក៏នៅពេលដែលយើងទំនេរពីការងារ ឬក៏នៅថ្ងៃចុងសប្តាហ៍។ អញ្ចឹងនៅពេលដែលយើង
ថ្ងៃចុងសប្តាហ៍ យើងចង់ជួបជុំគ្នាជាមួយមិត្តភក្តិ យើងអាចទៅញ៉ាំសាច់គោឡើងភ្នំនៅតាមហាងនានា
ឬក៏នៅផ្ទះរបស់យើងបាន។ អញ្ចឹងជាទូទៅសាច់គោឡើងភ្នំ គឺយើងញ៉ាំនៅតាមហាង
ព្រោះនៅតាមហាង គឺទើបមានឆ្នាំងធ្វើសាច់គោឡើងភ្នំ ចំណែកឯនៅតាមផ្ទះ
ភាគច្រើនគឺយើងអត់មានទេ អញ្ចឹងយើងពិបាកនៅក្នុងការធ្វើសាច់គោឡើងភ្នំញ៉ាំណាស់
ដូច្នេះហើយយើងតែងតែទៅញ៉ាំនៅតាមហាងនានាជាដើម។

ជាក់ស្តែងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានមនុស្សប្រុសស្រីចំនួនបីនាក់
ដែលយើងឃើញនារីទីមួយ គាត់ស្លៀកសំពត់ពណ៌សជើងខ្លី ហើយគាត់ពាក់អាវពណ៌រាងប្រផេះដៃខ្លី
គាត់កាត់សក់[ដឺមី] ឬក៏កាត់សក់សេះ យើងហៅថាកាត់សក់សេះ ដែលសក់របស់គាត់ គឺខាងមុខគឺខ្លី
ត្រឹមចិញ្ចើម ហើយខាងក្រោយគឺវែងត្រឹមស្មា។ នារីទីពីរគឺគាត់ពាក់អាវលឿងដៃខ្លី
ហើយស្លៀកខោជើងវែងពណ៌ខ្មៅ គាត់ចងសក់បួងឡើងទៅលើ។ ចំណែកឯបុរសម្នាក់
ដែលនៅក្នុងរូបភាពនេះ គឺគាត់ពាក់អាវដៃខ្លីពណ៌ខៀវ ហើយស្លៀកខោជើងវែងពណ៌ស
អញ្ចឹងពួកគេទាំងបីនាក់កំពុងតែពិភាក្សាគ្នា បានន័យថាពួកគេទាំងបីនាក់គឺជាមិត្តភក្តិនឹងគ្នា។
ដោយពួកគេកំពុងតែពិភាក្សាគ្នាអំពីការទៅរកកន្លែងញ៉ាំអាហារមួយ ព្រោះថាថ្ងៃនេះ
គឺជាថ្ងៃចុងសប្តាហ៍ ឬក៏ថ្ងៃនេះគឺជាថ្ងៃឈប់សម្រាក ដែលពួកគេទំនេរ មិនធ្វើការ
ឬក៏មិនសិក្សានោះទេនៅក្នុងថ្ងៃនេះ។ ដូច្នេះពួកគេជុំគ្នាដើម្បីបបួលគ្នាទៅញ៉ាំអាហារ។
អញ្ចឹងរូបភាពនេះ យើងឃើញបុរសម្នាក់ដែលគាត់ពាក់អាវខៀវហ្នឹង
គាត់កំពុងតែនិយាយអំពីសាច់គោឡើងភ្នំ។ អញ្ចឹងយើងឃើញដៃរបស់គាត់កំពុងតែ មួយចំហៀង
ឬក៏ដៃម្ខាងគាត់ទម្លាក់ចុះ ដៃម្ខាងទៀតគាត់ចង្អុល យកមេដៃចង្អុលមកខ្លួនគាត់
បានន័យថាគាត់ចង់ញ៉ាំសាច់គោឡើងភ្នំ ដែលគាត់និយាយទៅកាន់មិត្តភក្តិរបស់គាត់ទាំងពីរនាក់នោះ
គឺគាត់និយាយថា គាត់ចង់ញ៉ាំសាច់គោឡើងភ្នំ បន្ទាប់មកយើងឃើញនារីពីរនាក់
ដែលជាមិត្តភក្តិរបស់គាត់ ដែលឈរទល់មុខគាត់នោះ ដែលនារីពាក់អាវលឿងឈរខាងមុខ
នារីពាក់អាវពណ៌ប្រផេះឈរខាងក្រោយ គឺពួកគេទាំងពីរនាក់ ក៏បានលើកដៃឡើងទាំងពីរ
ប្រាប់ថាអត់បញ្ហា។ អញ្ចឹងបានន័យថាពួកគេទាំងពីរនាក់នោះ
ក៏ចង់ញ៉ាំសាច់គោឡើងភ្នំដូចបុរសម្នាក់នោះដែរ។ អញ្ចឹងហើយពួកគេលើកដៃឡើងទាំងពីរ
លើកដៃលាឡើង ដែលជាសញ្ញាមួយ ប្រាប់ថាពួកគេយល់ព្រមទៅញ៉ាំទាំងអស់គ្នា

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញនារីពីរនាក់នោះ គាត់ហាមាត់និយាយ ហើយទឹកមុខសប្បាយរីករាយ។ ព្រោះពួកគេទាំងបីនាក់ គឺយល់ព្រមទៅញ៉ាំសាច់គោឡើងភ្នំទាំងអស់គ្នា។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញ បន្ទាប់ពីពួកគេនិយាយគ្នា បបួលគ្នាទៅញ៉ាំសាច់គោឡើងភ្នំទាំងអស់គ្នាហើយ ពួកគេទាំងពីរនាក់ក៏បានជិះម៉ូតូចំនួនពីរ ដើម្បីទៅរកហាងញ៉ាំសាច់គោឡើងភ្នំ។ អញ្ចឹងយើងឃើញបុរសដែលពាក់អាវខៀវ គាត់ជិះម៉ូតូពណ៌បៃតងមួយ ដែលយើងឃើញម៉ូតូគឺមានកង់ពីរ ហើយមានកញ្ចក់មួយផងដែរ មានកញ្ចក់សងខាងសម្រាប់មើលក្រោយ។ ហើយម៉ូតូរបស់គាត់មានអំពូលភ្លើងខាងមុខមួយ និងខាងក្រោយមួយ ដើម្បីទុកបំភ្លឺផ្លូវ ហើយគាត់ជិះឌុបនារីម្នាក់ ដែលស្លៀកសំពត់ពណ៌ស និងពាក់អាវពណ៌ប្រផេះដៃខ្លី ដោយបុរសនៅខាងមុខដែលជាអ្នកឌុប គាត់ពាក់មួកសុវត្ថិភាពមួយផងដែរ ដើម្បីការពារសុវត្ថិភាពនៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍ ប៉ុន្តែនារីដែលនៅខាងក្រោយ គាត់អត់ពាក់មួកសុវត្ថិភាពទេ។ អញ្ចឹងការជិះម៉ូតូ ដោយអត់ពាក់មួកសុវត្ថិភាព គឺមានគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារតែនៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍ គឺវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ប៉ះពាល់ដល់ក្បាលរបស់យើង អញ្ចឹងធ្វើឲ្យយើងមានគ្រោះថ្នាក់ធ្ងន់ធ្ងរ អញ្ចឹងយើងជិះម៉ូតូ យើងត្រូវតែពាក់មួកសុវត្ថិភាព។ ហើយម្យ៉ាងវិញទៀត មិនពាក់មួកសុវត្ថិភាពនៅពេលជិះម៉ូតូ វាខុសនឹងច្បាប់ ដូច្នេះនៅពេលដែលប៉ូលិសឃើញ ប៉ូលិសអាចផាកពិន័យយើងបាន ដែលពិន័យជាទឹកប្រាក់ អញ្ចឹងយើងអាចខាតបង់ពេលវេលា ខាតបង់ទឹកប្រាក់ ដោយសារតែយើងធ្វេសប្រហែស មិនពាក់មួកសុវត្ថិភាពនៅពេលជិះម៉ូតូ។ ហើយម៉ូតូដែលនៅពីក្រោយ យើងឃើញមាននារីម្នាក់ ដែលពាក់អាវពណ៌លឿង អញ្ចឹងនារីដែលពាក់អាវពណ៌លឿង គាត់ជិះម៉ូតូពណ៌ទឹកក្រូច ដែលម៉ូតូរបស់គាត់ដូចគ្នាទៅនឹងម៉ូតូរបស់បុរសម្នាក់នោះដែរ ប៉ុន្តែខុសគ្នាពណ៌ គឺនារីម្នាក់នោះ គាត់ជិះពណ៌ទឹកក្រូច ហើយមួកសុវត្ថិភាពរបស់នារីម្នាក់នោះ គឺពាក់ពណ៌បៃតង អញ្ចឹងនារីពណ៌លឿង គាត់មានម៉ូតូមួយ និងបុរសដែលពាក់អាវពណ៌ខៀវ គាត់មានម៉ូតូមួយ។ ដោយឡែកនារីដែលពាក់អាវពណ៌ប្រផេះនិងស្លៀកសំពត់ស គាត់អត់មានម៉ូតូទេ។ ដូច្នេះហើយគាត់ជិះជាមួយនឹងបុរសដែលពាក់អាវពណ៌ខៀវ ដោយសារតែបុរសដែលពាក់អាវពណ៌ខៀវ គាត់គឺជាមនុស្សប្រុស អញ្ចឹងគាត់ងាយស្រួលនៅក្នុងការឌុបមនុស្សម្នាក់ផ្សេងទៀត ដោយឡែកនារីដែលពាក់អាវពណ៌លឿង គាត់ជាមនុស្សស្រី អញ្ចឹងគាត់អត់សូវមានកម្លាំងទេ ដូច្នេះគាត់ពិបាកនៅក្នុងការឌុបគ្នា ដូច្នេះហើយទើបនារីពាក់អាវពណ៌ប្រផេះ គាត់ជិះម៉ូតូជាមួយនឹងបុរសដែលពាក់អាវពណ៌ខៀវ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែគាត់មានកម្លាំងខ្លាំង ដូច្នេះគាត់អាចឱបមនុស្សបានងាយស្រួល
ជិះម៉ូតូឱបគ្នាបានងាយស្រួល។

បន្ទាប់មករូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា
ក្រោយពីពួកគេជិះម៉ូតូឱបគ្នាបានបន្តិចក្រោយមក
ពួកគេក៏បានមកដល់ហាងលក់សាច់គោឡើងភ្នំមួយកន្លែង
អញ្ចឹងពួកគេបានដល់ហាងសាច់គោឡើងភ្នំហើយ ដូច្នេះពួកគេក៏បានរកកន្លែងអង្គុយ
ដោយពួកគេមានគ្នាបីនាក់ ដូច្នេះពួកគេក៏អង្គុយនៅក្នុងតុមូលមួយ។ អញ្ចឹងនៅក្នុងរូបភាពទី ៣
យើងឃើញមានតុមូលមួយ ហើយពួកគេទាំងបីនាក់នោះ កំពុងតែអង្គុយកៅអីមួយម្នាក់ៗ
ដោយអង្គុយជារាងត្រីកោណ អញ្ចឹងនៅពេលដែលពួកគេអង្គុយជារាងត្រីកោណ
ពួកគេអាចមើលឃើញមុខគ្នាច្បាស់ ហើយអាចនិយាយលេងជាមួយគ្នាបានយ៉ាងងាយស្រួល។
បន្ទាប់មកយើងឃើញនារីដែលពាក់អាវលឿង គាត់ដាក់ដៃទាំងពីរនៅលើតុ
គាត់ដាក់ដៃទាំងពីរនៅលើតុ ហើយនិយាយគ្នាជាមួយនឹងមិត្តភក្តិគាត់ទាំងបីនាក់
ដោយនារីពាក់អាវស គាត់ក៏ដាក់ដៃលើតុដែរ គាត់ឱបដៃ ដាក់ដៃលើតុ
ហើយក៏និយាយគ្នាជាមួយនឹងនារីដែលពាក់អាវលឿង។ ចំណែកឯបុរសដែលពាក់អាវខៀវ
គាត់អង្គុយស្តាប់គេនិយាយគ្នា ដោយសារតែគាត់ជាមនុស្សប្រុស ដូច្នេះពេលខ្លះ
គឺពិបាកនឹងនិយាយគ្នាជាមួយនឹងមនុស្សស្រី ដោយសារតែមនុស្សស្រី គាត់មានរឿងផ្សេងៗ
ចែករំលែកជាមួយនឹងមនុស្សស្រីគ្នាគាត់។ ក៏ប៉ុន្តែមនុស្សប្រុស
គឺអត់សូវមានរឿងនិយាយជាមួយនឹងមនុស្សស្រីនោះទេ ដូច្នេះគាត់អង្គុយស្តាប់គេនិយាយ
ដោយគាត់មិននិយាយអ្វីនោះទេពេលនោះ។ ក៏ប៉ុន្តែពេលក្រោយ នៅពេលដែលពួកគេកំពុងតែញ៉ាំ
ពួកគាត់អាចនិយាយគ្នាលេង អំពីការងារ អំពីការសិក្សាជាដើម ទាំងបីនាក់តែម្តង។
ហើយនៅក្នុងរូបភាពទី ៣ នេះផងដែរ យើងឃើញមានអ្នកបម្រើ ឬក៏អ្នកលក់ គាត់បានលើកឆ្នាំង
លើកចង្រ្កានជាមួយនឹងឆ្នាំងសាច់គោឡើងភ្នំមកដាក់នៅលើតុរបស់អ្នកទាំងបី។ អញ្ចឹងបានន័យថា
នៅពេលដែលគាត់មកដល់អង្គុយនៅក្នុងតុភ្លាម គាត់បានហៅសាច់គោឡើងភ្នំមួយឆ្នាំង
ដូច្នេះអ្នកបម្រើក៏បានយកឆ្នាំងមួយ ដែលមានចង្រ្កាននៅក្នុងនោះផងដែរ មកដាក់នៅលើតុ
ប៉ុន្តែដោយសារតែក្តៅ ឆ្នាំងនោះក្តៅ ហើយនិងចង្រ្កានក្តៅ
ដូច្នេះយើងឃើញមានផ្សែងហុយចេញពីឆ្នាំង។ អញ្ចឹងសាច់គោឡើងភ្នំ
ធម្មតាគឺដាក់ឆ្នាំងជាប់ជាមួយនឹងចង្រ្កាន ដែលកំពុងតែដុតភ្លើង ដូច្នេះវាក្តៅ
អញ្ចឹងដើម្បីលើកចង្រ្កាននោះបាន អ្នកលក់ ឬក៏អ្នកបម្រើ ត្រូវការកន្សែងទ្រាប់ដៃ។
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញ អ្នកលក់នោះ គាត់បានយកកន្សែងមួយ
ដែលមានពណ៌ផ្កាឈូក មកទ្រាប់ចង្រ្កាននោះ ដើម្បីកុំឲ្យក្តៅដៃ។ អញ្ចឹងនៅពេលដែលគាត់ទ្រាប់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់អត់ក្ដៅទេ ហើយគាត់ងាយស្រួលក្នុងការលើកចង្ក្រាននោះយកមកឲ្យភ្ញៀវ
ដូច្នេះហើយទើបយើងឃើញគាត់បានយកកន្សែងពណ៌ផ្កាឈូកមួយទ្រដៃ ឬក៏ទ្រាប់ដៃរបស់គាត់
ដើម្បីលើកចង្ក្រានមកឲ្យភ្ញៀវ ដែលចង្ក្រាននោះកំពុងតែក្ដៅ
ហើយនិងឃើញមានផ្សែងហុយយ៉ាងខ្លាំង។ អញ្ចឹងអ្នកបម្រើបានយកឆ្នាំង
ឬក៏ចង្ក្រានសាច់គោឡើងភ្នំ មកដាក់នៅលើតុឲ្យអ្នកទាំងបីនាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ បន្ទាប់ពីអ្នកបម្រើ
គាត់បានយកចង្ក្រានសាច់គោឡើងភ្នំមកដាក់នៅលើតុហើយ។ បន្ទាប់មកទៀត
គាត់ក៏បានទៅរុញរទេះមួយ ដែលមានចាន មានកែវ មានភេសជ្ជៈ
និងមានទឹកកកនៅលើរទេះនោះផងដែរ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញអ្នកបម្រើនោះ
គាត់ពាក់អាវពណ៌ប្រផេះ ដៃខ្លី ស្លៀកខោជើងវែងពណ៌ខ្មៅ ហើយគាត់មានពាក់អៀមមួយផងដែរ
ដែលអៀមនោះ គឺជាអៀមពណ៌ស។ អញ្ចឹងជាទូទៅនៅតាមហាងនីមួយៗ
អ្នកបម្រើតែងតែពាក់អៀម ដើម្បីការពារកុំឲ្យប្រឡាក់អាវរបស់គាត់
ដើម្បីកុំឲ្យម្ហូបខ្ទាតប្រឡាក់អាវរបស់គាត់ និងដើម្បីរក្សាអនាម័យ ដូច្នេះគាត់ត្រូវពាក់អៀមមួយ
ដើម្បីការពារកុំឲ្យម្ហូបខ្ទាតមកប្រឡាក់អាវរបស់គាត់។
យើងឃើញដៃទាំងពីររបស់អ្នកបម្រើកំពុងតែចាប់កាន់បង្កាន់ដៃរបស់រទេះមួយ
ដើម្បីរុញរទេះនោះមកឲ្យ មកដល់តុអ្នកទាំងបី ដែលបានចូលអង្គុយនៅក្នុងតុ។ អញ្ចឹងនៅលើរទេះ
ដែលអ្នកបម្រើកំពុងតែរុញនោះ គឺយើងឃើញមានពីរថ្នាក់
ដែលថ្នាក់ទីមួយយើងឃើញមានភេសជ្ជៈពីរដប អញ្ចឹងចំនួន ភេសជ្ជៈចំនួនពីរដប
ភេសជ្ជៈនោះអាចជាស្រា ឬក៏អាចជាស្រាបៀរ ឬក៏អាចជាទឹកសុទ្ធនិងទឹកក្រូចជាដើម
ដើម្បីឲ្យអ្នកទាំងបីនោះញ៉ាំ ហើយនៅក្បែរដបភេសជ្ជៈទាំងពីរដបនោះ គឺយើងឃើញមានធុងមួយ
ដែលធុងនោះពណ៌បៃតង ហើយនៅក្នុងធុងនោះ យើងឃើញមានទឹកកកជាច្រើនផងដែរ
អញ្ចឹងវាជាទឹកកកអនាម័យ ឬក៏ជាទឹកកកដុំ ដែលគេកាប់រួចរាល់ហើយ។
អញ្ចឹងប្រសិនបើវាជាទឹកកកអនាម័យ គឺយើងអត់ត្រូវការកាប់វាជាដុំតូចៗនោះទេ
ក៏ប៉ុន្តែប្រសិនបើវាជាទឹកកកដុំ យើងត្រូវកាប់វាជាដុំតូចៗ ដើម្បីដាក់ចូលទៅក្នុងកែវ
លាយជាមួយនឹងភេសជ្ជៈ ដើម្បីញ៉ាំឲ្យមានភាពត្រជាក់ អញ្ចឹងទឹកកកគឺត្រជាក់
ដូច្នេះនៅពេលដែលយើងដាក់ជាមួយភេសជ្ជៈ ភេសជ្ជៈរបស់យើងនឹងត្រជាក់ដូចទឹកកកអញ្ចឹង។
ចំណែកឯនៅថ្នាក់ទីពីរនៃរទេះនោះ នៅថ្នាក់ទីពីរ យើងឃើញមានចាន មានកែវ
មានស្លាបព្រាផងដែរ។ អញ្ចឹងគេចែកចេញជាពីរថ្នាក់ ដែលថ្នាក់ទីមួយដាក់ភេសជ្ជៈ
និងថ្នាក់ទីពីរដាក់ចាន ដាក់កែវ ដើម្បីឲ្យភ្ញៀវ។ អញ្ចឹងនៅក្នុងថ្នាក់ទីពីរ យើងឃើញមានកែវចំនួនបី
ដែលសម្រាប់ពួកគេចំនួនបីនាក់ផងដែរ។ អញ្ចឹងកែវទាំងនោះ គឺយកមកសម្រាប់ដាក់ភេសជ្ជៈ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីញ៉ាំ ហើយមានចានចំនួនប្រាំមួយ ដែលចានចំនួនប្រាំមួយនោះ
យើងឃើញមានចានគោមចំនួនបី និងចានសំប៉ែតចំនួនបី អញ្ចឹងដោយសារតែភ្ញៀវរបស់គាត់
មានចំនួនបីនាក់នៅក្នុងតុនេះ ដូច្នេះអ្នកបម្រើនោះ គាត់យកតែចានបី និងកែវបី ចានគោមបី
ចានសំប៉ែតបី មកឲ្យនោះទេ ព្រោះថាចំនួនមនុស្សតែបីនាក់ អញ្ចឹងគាត់យកតែបីៗមកតែប៉ុណ្ណោះ។
អញ្ចឹងចានគោម គឺយើងសម្រាប់ដាក់ទឹកស៊ុប ឯចានសំប៉ែតគឺយើងសម្រាប់ដាក់បាយ
ឬក៏ដាក់សាច់ដើម្បីញ៉ាំផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីពួកគេទទួលបានចាន បានកែវ
បានស្លាបព្រា បានភេសជ្ជៈ ហើយក៏ដូចជាបានធុងទឹកកកហើយ ហើយជាពិសេស
គេបានឆ្នាំងសម្រាប់ធ្វើសាច់គោឡើងភ្នំញ៉ាំហើយ ពេលនោះពួកគេក៏បានដើររើសម្ហូប
ដើម្បីយកទៅញ៉ាំ ដើម្បីយកទៅចម្អិននៅលើចង្ក្រាននោះ។ អញ្ចឹងដោយសារតែទីនេះគឺជាកន្លែង
យើងហៅថាអាហារប៊ូហ្វេ ដូច្នេះភ្ញៀវត្រូវដើររើសម្ហូបដោយខ្លួនឯង អ្វីដែលគេចង់ញ៉ាំ
គេត្រូវដើរយកដោយខ្លួនឯង។ អញ្ចឹងជាទូទៅនៅកន្លែងដែលមានអាហារប៊ូហ្វេ
ឬក៏អាហារសម្រាប់បម្រើខ្លួនឯង គឺយើងឃើញតែងតែឃើញគេដាក់
អ្នកលក់តែងតែដាក់អាហារផ្សេងៗដែលនៅឆៅ ឬក៏ឆ្អិនស្រាប់នៅលើតុមួយ ហើយមានថាសមួយ
សម្រាប់ដាក់ម្ហូបអាហារទាំងនោះ ដើម្បីឲ្យភ្ញៀវគាត់ដើរទៅរើស អញ្ចឹងភ្ញៀវគាត់មានសិទ្ធសម្រេច
បានន័យថាគាត់ចង់ញ៉ាំអ្វី គាត់យករបស់នោះ ដែលគាត់ ប្រសិនបើគាត់អត់ចង់ញ៉ាំទេ
គាត់មិនបាច់យកនោះទេ អញ្ចឹងគេអត់គិតលុយទេ ប៉ុន្តែប្រសិនបើគាត់ចង់ញ៉ាំ
គាត់គ្រាន់តែដើរទៅកន្លែងដែលដាក់អាហារប្រភេទដែលគាត់ចង់ញ៉ាំ
ហើយគាត់យកវែកដួសអាហារទាំងនោះដាក់នៅលើចាន បន្ទាប់មកគាត់យកមកតុគាត់
អញ្ចឹងគាត់អាចញ៉ាំអាហារនោះបានតែម្តង ដោយមិនចាំបាច់ហៅអ្នកបម្រើ ឲ្យមកបម្រើយើងនោះទេ
គឺយើងត្រូវតែឡើងចាប់ខ្លួនឯង។ ជាក់ស្តែងនៅក្នុងរូបភាពនេះ យើងឃើញមានតុមួយ តុវែង
ឬក៏ទូវែងមួយ ដែលនៅលើទូវែងនោះ គឺយើងឃើញមានថាស ឬក៏ចានដែកជាច្រើនសម្រាប់ដាក់ម្ហូប
ដែលយើងឃើញថាសទីមួយ គឺដាក់សាច់ជ្រូក ឬក៏សាច់គោ ឬក៏សាច់ត្រីនៅក្នុងនោះ។
អញ្ចឹងប្រសិនបើមានភ្ញៀវណាគាត់ចង់ញ៉ាំសាច់ជ្រូក គាត់អាចចាប់សាច់ជ្រូក
ភ្ញៀវណាដែលចង់ញ៉ាំសាច់ត្រី គាត់អាចចាប់សាច់ត្រី ហើយភ្ញៀវណាគាត់ចង់ញ៉ាំសាច់គោ
គាត់អាចចាប់សាច់គោចេញពីថាសនោះបាន។ ចំណែកឯថាសទីពីរ
យើងឃើញមានបន្លែពណ៌បៃតង អញ្ចឹងបន្លែពណ៌បៃតងអាចជាសាលាដ អាចជាជី
អាចជាស្ពៃជាដើម។ ដូច្នេះគេដាក់បែបនេះ ដើម្បីបំពេញតាមតម្រូវការភ្ញៀវ ថាគាត់ចង់ញ៉ាំបន្លែ
ឬគាត់ចង់ញ៉ាំសាច់ អញ្ចឹងប្រសិនបើគាត់ញ៉ាំបន្លែ គាត់អាចដួសបន្លែ ប្រសិនបើគាត់ចង់ញ៉ាំសាច់
គាត់អាចដួសសាច់ អញ្ចឹងគាត់ចង់ញ៉ាំអ្វី គឺដួសម្ហូបនោះតាមតម្រូវការរបស់គាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចំណែកឯថាសទីបី យើងឃើញមានពណ៌លឿង ដូចជាពោតជាដើម អញ្ចឹងអាចមានកូនពោត ឬក៏ស្នូលពោត ដើម្បីញ៉ាំជាមួយនឹងទឹកស៊ុប។ ហើយនៅក្នុងរូបភាពនេះ យើងឃើញមានដៃមួយ កំពុងតែកាន់ចាន ដៃរនៅលើចាននោះ គឺមានបន្លែពណ៌បៃតង មានសាច់ មានប៉េងប៉ោះជាដើម អញ្ចឹងគេកំពុងតែដួសម្ហូប ដែលជាអាហារប៊ូហ្វេនោះ ដាក់ក្នុងចាន ដើម្បីយកទៅចម្អិននៅលើចង្ក្រានសាច់គោឡើងភ្នំនោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា មានរូបភាពបន្លែ និងត្រីសាច់ជាច្រើន នៅលើនោះ នៅក្នុងរូបភាពទី ៦ នេះ ដែលរូបភាពនេះបញ្ជាក់ថា ការញ៉ាំសាច់គោឡើងភ្នំ យើងមិនមែនបាននំយថាយើងមកញ៉ាំតែសាច់គោនោះទេ ដោយគ្រឿងសាច់គោឡើងភ្នំមានជាច្រើន ដូចជាបន្លែ មានដូចជាត្រី មានដូចជាគ្រឿងសមុទ្រផងដែរ ដែលនៅក្នុងរូបភាពនេះ យើងឃើញមានការ៉ុត យើងឃើញមានការ៉ុតចំនួនពីរមើម អញ្ចឹងបាននំយថាពួកគេបានយកការ៉ុតចំនួនពីរមើម មានដំឡូងបារាំងចំនួនពីរ ហើយមានខាត់ណា មានជី មានសាច់គោ មានត្រី មានមឹក អញ្ចឹងយើងឃើញត្រី យើងឃើញត្រីកំពុងតែងាប់ អញ្ចឹងបាននំយថាត្រីងាប់ហើយ ហើយមានមឹកមួយផងដែរ ដែលមឹកនោះគេហៅថាមឹកបំពង់ ហើយយើងឃើញនៅចំកណ្តាលគឺមានទឹកជ្រលក់ អញ្ចឹងដើម្បីញ៉ាំសាច់គោឡើងភ្នំ គឺយើងត្រូវការទឹកជ្រលក់ជាមួយនឹងបន្លែ ព្រោះថាសាច់គោឡើងភ្នំគឺវាសាប បាននំយថាសាច់ ឬក៏ត្រី ឬក៏មឹក ឬក៏គ្រឿងសមុទ្រនោះគឺសាប ដូច្នេះយើងត្រូវញ៉ាំទឹកជ្រលក់ផងដែរ។ ហើយនៅក្នុងរូបភាពនេះ យើងឃើញបាយមួយចាន អញ្ចឹងយើងញ៉ាំបាយជាមួយនឹងសាច់គោឡើងភ្នំ គឺដើម្បីធ្វើឲ្យយើងឆ្អែត អញ្ចឹងប្រសិនបើយើងញ៉ាំបាយ យើងអត់ចាំបាច់ញ៉ាំបាយនៅផ្ទះទៀតទេ គឺយើងញ៉ាំបាយនៅក្នុងហាងនោះ គឺយើងឆ្អែតតែម្តង ប៉ុន្តែពេលខ្លះ គឺយើងអត់ញ៉ាំបាយក៏បានដែរ គឺយើងញ៉ាំតែសាច់ ហើយយើងឃើញមានផ្សិតផងដែរ ដែលផ្សិតនោះគឺជាផ្សិតម្ជុល យើងហៅថាផ្សិតម្ជុល ឬក៏ផ្សិតអំបោះ ដែលផ្សិតនោះគឺរាងតូចៗហើយវែង ប៉ុន្តែវាញ៉ាំជាមួយស៊ុប គឺមានរសជាតិឆ្ងាញ់។ អញ្ចឹងនៅក្នុងរូបភាពទី ៦ នេះ គឺយើងឃើញមានគ្រឿងផ្សំជាច្រើន ក៏ដូចជាសាច់ត្រីជាច្រើន ត្រីសាច់ជាច្រើន ដែលអាចយកទៅញ៉ាំជាមួយនឹងមុខម្ហូបសាច់គោឡើងភ្នំ អញ្ចឹងទោះបីជាវាឈ្មោះថាសាច់គោឡើងភ្នំក៏ដោយ អញ្ចឹងយើងអាចយកត្រី យកមឹក ឬក៏យកសាច់ជ្រូកទៅអាំងក៏បានដែរ គ្រាន់តែឈ្មោះរបស់វា គេហៅថា សាច់គោឡើងភ្នំ ក៏ប៉ុន្តែមិនមែនញ៉ាំបានតែសាច់គោនោះទេ គឺយើងអាចញ៉ាំសាច់ជ្រូក សាច់ត្រី សាច់មឹកអីក៏បានដែរ ហើយមានបន្លែផងដែរ។ ជាក់ស្តែងនៅក្នុងរូបភាពទី ៦ គឺយើងឃើញមានគ្រឿងផ្សំសម្រាប់មុខម្ហូបសាច់គោឡើងភ្នំនេះជាច្រើន មានដូចជាការ៉ុត ដំឡូងបារាំង មានផ្សិត មានខាត់ណា មានជី មានសាច់ជ្រូក មានត្រី មានមឹក និងមានបាយផងដែរ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញមានរូបភាពចំនួនបី នៅក្នុងរូបភាពនេះ ដោយនៅខាងឆ្វេងដៃ គឺយើងឃើញមានចង្ក្រាន ឬក៏ឆ្នាំងសាច់គោឡើងភ្នំ ដែលយើងឃើញឆ្នាំងនេះ គឺជារាងឆ្នាំងមួយដែលមានលក្ខណៈខុសប្លែកពីឆ្នាំងធម្មតា ដោយឆ្នាំងនេះ គឺមានរាងដូចជាឆ្នាំងយើងធម្មតាមួយផ្នែក ហើយចំកណ្ដាលគឺមានទួលចំនួនមួយ។ អញ្ចឹងទួលចំកណ្ដាលនោះ គឺជា គេធ្វើជារាងដូចជាបន្ទះអាំងសាច់ សម្រាប់អាំងសាច់គោ ឬក៏សាច់ជ្រូក ឬក៏សាច់ត្រី ចំណែកឯនៅខាងៗទួលនោះ គឺយើងឃើញមានទឹកស៊ុប។ អញ្ចឹងឆ្នាំងនេះគឺមានរាងកោង រាងកោងចុះក្រោម ហើយប៉ោងកណ្ដាលដើម្បីអាំងសាច់ អញ្ចឹងផ្នែកដែលកោងចុះក្រោម គឺយើងដាក់ទឹកស៊ុប ចំណែកឯផ្នែកដែលប៉ោងឡើងលើ គឺយើងដាក់សាច់។ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពទីប្រាំពីរដែលនៅខាងឆ្វេងដៃនេះ គឺយើងឃើញមានទឹកស៊ុបនៅក្នុងឆ្នាំងនោះជាច្រើន ហើយចំណែកឯផ្នែកកណ្ដាល ដែលប៉ោងឡើងផុតពីទឹកស៊ុបនោះ គឺយើងឃើញមាន គេកំពុងតែដាក់សាច់អាំងនៅក្នុងទឹកស៊ុបនោះ នៅក្នុងឆ្នាំងនោះ អញ្ចឹងសាច់កំពុងតែអាំងនៅលើឆ្នាំង ឬក៏នៅលើបន្ទះអាំងសាច់ ចំណែកឯទឹកស៊ុបគឺដាក់នៅសងខាង ហើយទឹកស៊ុបនោះគឺក្ដៅ ដោយសារតែចង្ក្រាននោះ គឺមានភ្លើងនៅក្នុងនោះ ដូច្នេះវាធ្វើឲ្យវាក្ដៅ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានដៃមួយកំពុងតែចាប់ចង្កឹះ ចាប់ចង្កឹះ ហើយយកសាច់មកដាក់នៅលើចង្អើរអាំងសាច់ ដែល[ជា]នៅក្នុងចង្ក្រានសាច់គោឡើងភ្នំនោះ។ បន្ទាប់មកទៀតរូបភាពដែលនៅកណ្ដាល រូបភាពទី ៧ ដដែល ហើយរូបភាពនោះគឺនៅកណ្ដាល អញ្ចឹងយើងឃើញ បន្ទាប់ពីគេដាក់អាំងសាច់នៅលើចង្អើរអាំងសាច់រួចហើយ ពួកគេក៏ចាប់ផ្ដើមដាក់បន្លែ ចូលទៅក្នុងទឹកស៊ុបដែលនៅខាងៗ អញ្ចឹងបន្លែទាំងអស់ដែលគេចាប់មកអម្បាញ់មិញ គឺគេយកទៅដាក់នៅក្នុងទឹកស៊ុប។ អញ្ចឹងជាទូទៅទឹកស៊ុបដែលអ្នកលក់ឲ្យមក គឺអត់ទាន់មានបន្លែនោះទេ គឺមានតែទឹកដែលមានរសជាតិទឹកស៊ុប ហើយចំពោះគ្រឿងផ្សំនិងបន្លែ គឺយើងអ្នកដាក់ខ្លួនឯង។ អញ្ចឹងជាក់ស្ដែងអម្បាញ់មិញ គេបានទៅយកបន្លែ នៅក្នុងតុអាហារប៊ូហ្វេនោះ ដូច្នេះហើយនៅពេលដែលគេយកមកដល់តុរបស់គេ គេយកបន្លែទាំងអស់ដាក់ចូលទៅក្នុងទឹកស៊ុប ដើម្បីឲ្យវាឆ្អិន អញ្ចឹងបន្លែគឺជាបន្លែឆៅ ដូច្នេះដើម្បីញ៉ាំបាន យើងត្រូវតែស្រុះវាជាមួយទឹកស៊ុបឲ្យឆ្អិនជាមុនសិន។ ដែលជាក់ស្ដែងនៅក្នុងរូបភាពនេះ យើងឃើញដៃមួយកំពុងតែចាប់ចង្កឹះ ដែលយកចង្កឹះនោះចាប់ផ្កាខាត់ណាដាក់ចូលទៅក្នុងទឹកស៊ុប ហើយនៅក្នុងទឹកស៊ុបនោះ យើងឃើញមានបន្លែផ្សេងៗទៀតជាច្រើន ដូចជាស្ពៃ ដូចជាការ៉ុត ដូចជាជី ដូចជាផ្សិតជាដើម ដែលគេដាក់នៅក្នុងឆ្នាំងទឹកស៊ុបនោះ ហើយសាច់កំពុងតែអាំងនៅលើចង្អើរ នៅក្នុងឆ្នាំងសាច់គោឡើងភ្នំនោះ ដែលយើងឃើញកំពុងតែក្ដៅ ហើយមានផ្សែងហុយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលបញ្ចេញក្លិនយ៉ាងឈ្ងុយ ដែលមើលទៅគួរឲ្យចង់ញ៉ាំ
ដោយមើលទៅទំនងជាមានរសជាតិឆ្ងាញ់។ ចំណែកឯរូបភាពនៅខាងស្តាំដៃនៅក្នុងរូបភាពទី ៧ នេះ
យើងឃើញសាច់គោ ដែលអាំងនៅលើចង្ក្រាននោះ គឺឆ្អិនរួចរាល់ហើយ គឺសាច់គោនោះបានឆ្អិន
ដូច្នេះហើយយើងឃើញពួកគេក៏បានចាប់សាច់គោនោះដើម្បីយកទៅញ៉ាំ អញ្ចឹងយើងឃើញចង្កឹះ
ដៃចាប់ចង្កឹះ ហើយយកស្រមកទៅចាប់សាច់គោ ដែលនៅក្នុងឆ្នាំងនោះយកមកញ៉ាំ
ចំណែកឯទឹកស៊ុបក៏បានឆ្អិនហើយដែរ ដែលទឹកស៊ុបនោះ គឺមានបន្លែជាច្រើន ដែលកំពុងតែពុះ
ឬក៏កំពុងតែឆ្អិន បន្លែនៅក្នុងទឹកស៊ុបនោះឆ្អិនហើយ ដោយសារតែទឹកស៊ុបក្តៅ
ដូច្នេះយើងស្រុះតែមួយស្របក់ ឬក៏មួយសន្ទុះ គឺបន្លែនោះអាចឆ្អិន អាចញ៉ាំបានតែម្តង។
ជាក់ស្តែងនៅក្នុងរូបភាពទី ៧ នេះ គឺសាច់គោក៏ឆ្អិន ដោយសាច់គោដាក់នៅលើចង្អើរអាំងក្តៅ
ដូច្នេះវាឆាប់ឆ្អិន ហើយបន្លែនៅក្នុងទឹកស៊ុបក៏ឆ្អិន ដូច្នេះយើងអាចញ៉ាំបានទាំងអស់តែម្តង
គឺយើងញ៉ាំបានទាំងបន្លែ ញ៉ាំបានទាំងទឹកស៊ុប ក៏ដូចជាសាច់ដែលអាំងនៅលើចង្អើរផងដែរ។

បន្ទាប់មករូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញ
បន្ទាប់ពីគេចាប់សាច់ចេញពីចង្ក្រានរួចរាល់ហើយ យើងឃើញគេយកសាច់នោះ
មកជ្រលក់នៅក្នុងទឹកជ្រលក់ ដូច្នេះដោយសារតែសាច់គោឡើងភ្នំគឺមានរសជាតិសាប
ដោយសារសាច់អត់មានប្រឡាក់គ្រឿងនោះទេ អញ្ចឹងសាច់ដែលយើងយកមកធ្វើសាច់គោឡើងភ្នំ
គឺយើងអត់ប្រឡាក់គ្រឿងវានោះទេ គឺវាមានរសជាតិសាប។ ដូច្នេះដើម្បីញ៉ាំឲ្យបានឆ្ងាញ់
គឺយើងយកមកជ្រលក់នឹងទឹកជ្រលក់
ជាក់ស្តែងទឹកជ្រលក់ដែលសម្រាប់ញ៉ាំជាមួយនឹងសាច់គោឡើងភ្នំ គឺមានរសជាតិច្រើនរសជាតិ
ហើយក៏មានរសជាតិផ្សេងៗជាច្រើនផងដែរ ដូចជារសជាតិហឹរ រសជាតិជូរ រសជាតិប្រៃ
រសជាតិជូរអែមផងដែរ។ អញ្ចឹងវាមានរសជាតិច្រើន ទៅតាមចំណង់ចំណូលចិត្តរបស់អ្នកញ៉ាំ
ដោយអ្នកខ្លះគាត់ចូលចិត្តហឹរ ដូច្នេះគាត់យកទឹកជ្រលក់រសជាតិហឹរ ចំណែកអ្នកខ្លះគាត់ចូលចិត្តជូរ
អញ្ចឹងទៅគាត់ក៏យកទឹកជ្រលក់រសជាតិជូរ ហើយអ្នកខ្លះទៀតគាត់ចូលចិត្តរសជាតិជូរអែម
ដូច្នេះគាត់យកទឹកជ្រលក់រសជាតិជូរអែម។ អញ្ចឹងនៅតាមហាងនីមួយៗគេតែងតែធ្វើ
ឬក៏គេតែងតែផលិតទឹកជ្រលក់ច្រើនប្រភេទ ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន
ហើយគេយកទឹកជ្រលក់ទាំងអស់នោះ មកដាក់នៅលើតុអតិថិជនតែម្តង
ដើម្បីឲ្យអតិថិជនជ្រើសរើសខ្លួនឯងថាគេចង់ញ៉ាំទឹកជ្រលក់ប្រភេទណា
អញ្ចឹងនៅពេលដែលគេយកសាច់មកជ្រលក់ទឹកជ្រលក់
ធ្វើឲ្យសាច់នោះមានជាប់នូវរសជាតិផ្សេងៗទៅតាមទឹកជ្រលក់
អញ្ចឹងធ្វើឲ្យសាច់របស់យើងកាន់តែមានរសជាតិឆ្ងាញ់ថែមមួយកម្រិតទៀត។ ដែលនៅក្នុងរូបភាពទី
៨ យើងឃើញចានទឹកជ្រលក់ពណ៌លឿង ហើយនៅក្នុងនោះគឺមានទឹកជ្រលក់ផងដែរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងយកសាច់ទៅជ្រលក់ទៅនឹងទឹកជ្រលក់
ហើយយើងឃើញទឹកជ្រលក់កំពុងតែជាប់សាច់នោះ
អញ្ចឹងគេយកសាច់ទៅជ្រលក់ក្នុងទឹកជ្រលក់ហើយ បន្ទាប់មកគេយកមកញ៉ាំ
ដែលយើងឃើញនៅក្បែរចានទឹកជ្រលក់ យើងឃើញមានកែវទឹកចំនួនមួយ អញ្ចឹងកែវនោះ
គឺកំពុងតែដាក់ទឹកជិតពេញ អញ្ចឹងទឹកជិតពេញកែវសម្រាប់ញ៉ាំ អញ្ចឹងពេលខ្លះ
យើងញ៉ាំទឹកជ្រលក់នោះហឹរ ឬក៏ប្រៃ ឬក៏ផ្អែម ឬក៏ជូរពេក អញ្ចឹងវាអាចធ្វើឲ្យយើងស្រេកទឹក
ដូច្នេះយើងត្រូវមានកែវទឹកមួយនៅក្បែរខ្លួនយើង នៅពេលដែលយើងញ៉ាំហើយ
យើងអាចញ៉ាំទឹកនោះបន្ថែមបាន ព្រោះទឹកអាចបន្សាបជាតិផ្អែម អាចបន្សាបជាតិប្រៃ
ហើយនិងអាចបន្សាបជាតិហឹរបាន កុំឲ្យវាហឹរខ្លាំងពេក ឬក៏កុំឲ្យវាប្រៃខ្លាំងពេក
អញ្ចឹងនៅពេលដែលយើងហឹរខ្លាំង យើងយកទឹកមួយកែវញ៉ាំ
នោះវានឹងអាចកាត់បន្ថយភាពហឹររបស់យើងបាន។ ហើយនៅក្បែរចានទឹកជ្រលក់មួយទៀតផងដែរ
គឺយើងឃើញមានចានបាយចំនួនមួយ អញ្ចឹងគេញ៉ាំសាច់គោឡើងភ្នំជាមួយនឹងបាយ
ដែលយើងឃើញចានបាយពណ៌ក្រហម ដែលមានបាយនៅក្នុងនោះជាច្រើន
ដែលយើងដួសមកដាក់ឡើងកំពុងចានតែម្តង អញ្ចឹងបាយជាច្រើននៅក្នុងចាន
ហើយគេញ៉ាំសាច់គោឡើងភ្នំជាមួយនឹងបាយ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ គឺយើងឃើញមានមនុស្សចំនួនបីនាក់នោះ
ដែលមានមនុស្សប្រុសស្រី ដែលមិត្តភក្តិទាំងបីនាក់នោះ គាត់កំពុងតែអង្គុយញ៉ាំសាច់គោឡើងភ្នំ
ដោយពួកគេញ៉ាំបណ្តើរ និយាយគ្នាលេងបណ្តើរ អំពីការសិក្សា ក៏ដូចជាអំពីការងារ
ឬក៏អំពីដំណើរកម្សាន្តផ្សេងៗ។ ដោយសារតែថ្ងៃនេះគឺជាថ្ងៃសម្រាក ឬក៏ថ្ងៃនេះគឺជាថ្ងៃដែលទំនេរ
ដែលពួកគេអត់ធ្វើការ ដែលពួកគេឈប់សម្រាកពីការងារ ដូច្នេះពួកគេក៏បានមកជុំគ្នា
ដើម្បីញ៉ាំសាច់គោឡើងភ្នំនៅក្នុងហាង ដែលនៅក្នុងរូបភាពនេះ
យើងឃើញនារីដែលពាក់អាវពណ៌ប្រផេះដៃខ្លីនោះ គាត់កំពុងតែអង្គុយដោយដាក់ដៃម្ខាងនៅលើតុ
ដៃម្ខាងទៀតកំពុងតែចាប់សាច់យកមកញ៉ាំ អញ្ចឹងខាងមុខនារីនោះ
យើងឃើញមានចានបាយចំនួនមួយ ចានសំប៉ែតចំនួនមួយ និងចានទឹកជ្រលក់ចំនួនមួយ
ដោយនារីម្នាក់នោះ ត្រូវយកសាច់មកជ្រលក់នឹងទឹកជ្រលក់ មុខពេលដែលគាត់ញ៉ាំជាមួយនឹងបាយ
ដើម្បីឲ្យសាច់នោះមានរសជាតិឆ្ងាញ់ ហើយគាត់មានកែវទឹកចំនួនមួយផងដែរ ដែលនៅក្បែរនោះ
ហើយបន្ទាប់មកយើងឃើញបុរសដែលពាក់អាវពណ៌ខៀវ គឺគាត់មានចានមួយដូចគ្នា ចានបាយមួយ
ចានទឹកជ្រលក់មួយ ចានសំប៉ែតមួយ ហើយនិងកែវទឹកមួយដូចគ្នា ដែលបុរសនោះ
គាត់កំពុងតែអង្គុយដាក់ដៃលើតុ ហើយសម្លឹងទៅរកនារីដែលពាក់អាវពណ៌ប្រផេះនោះ
ហើយកំពុងតែនិយាយគ្នាលេងយ៉ាងសប្បាយ ដូចគ្នាផងដែរ ចំពោះនារីពាក់អាវលឿង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានអង្គុយ ហើយដាក់ដៃនៅលើតុដូចគ្នា ដើម្បីនិយាយគ្នា ដែលនៅចំកណ្ដាលតុនោះ យើងឃើញមានចង្ក្រាន ហើយនិងឆ្នាំងសាច់គោឡើងភ្នំដែលកំពុងតែហុយ ដែលកំពុងតែក្ដៅ បានន័យថាសាច់គោកំពុងតែឆ្អិន ជាមួយនឹងបន្លែក៏ឆ្អិនហើយដែរ ដូច្នេះពួកគេអាចញ៉ាំបានបណ្ដើរ និយាយគ្នាលេងបណ្ដើរ អញ្ចឹងនៅក្បែរចង្ក្រាននោះយើងឃើញមានធុងទឹកកកមួយផងដែរ ដែលធុងទឹកកកនោះ គឺមានទឹកកកនៅក្នុងនោះពេញ។ ហើយយើងឃើញគាត់ដាក់ដបភេសជ្ជៈ ឬក៏ដបទឹកនៅក្នុងធុងទឹកកកនោះ ដើម្បីឲ្យត្រជាក់។ អញ្ចឹងពេលខ្លះ ប្រសិនបើយើងអត់ចូលចិត្តញ៉ាំទឹកកក ឬក៏អត់ចូលចិត្តដាក់លាយទឹកកកទេ យើងអាចក្លាសេ យើងហៅថាក្លាសេ អញ្ចឹងយើងអាចក្លាសេដបទឹករបស់យើងនៅក្នុងធុងទឹកកក អញ្ចឹងនៅពេលដែលយើងដាក់ដបទឹកចូលទៅក្នុងធុងទឹកកក គឺវាអាចធ្វើឲ្យទឹករបស់យើងត្រជាក់ផងដែរ អញ្ចឹងយើងអាចញ៉ាំដោយមិនបាច់ដាក់ថែមទឹកកកនោះទេ ជាក់ស្ដែងនៅក្នុងរូបភាពនេះ ពួកគេបានយកដបទឹកដាក់ទៅក្នុងធុងទឹកកក ដើម្បីធ្វើការក្លាសេវាឲ្យត្រជាក់ ដូច្នេះពួកគេអត់ចាំបាច់ញ៉ាំលាយទឹកកកនោះទេ។ អញ្ចឹងនៅក្នុងរូបភាពទី ៩ ពួកគេទាំងបីនាក់ កំពុងតែញ៉ាំសាច់គោឡើងភ្នំ ដោយពួកគេញ៉ាំបណ្ដើរ និយាយគ្នាលេងបណ្ដើរ អំពីការងាររបស់ពួកគេ យ៉ាងសប្បាយរីករាយ នៅក្នុងថ្ងៃចុងសប្ដាហ៍ ឬនៅថ្ងៃសម្រាក។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ គឺយើងឃើញថា បន្ទាប់ពីពួកគេញ៉ាំហើយ ពួកគេញ៉ាំសាច់គោឡើងភ្នំនោះអស់ហើយ ដោយសារតែយើងឃើញចង្ក្រាន ដែលនៅកណ្ដាលតុនោះ គឺអត់មានសាច់ទៀតទេ ហើយទឹកស៊ុបនិងបន្លែទាំងអស់ក៏អស់ផងដែរ គឺពួកគេបានញ៉ាំទាំងអស់តែម្ដង គឺអត់មានសល់នៅក្នុងចង្ក្រាន នៅក្នុងឆ្នាំងនោះទេ ដូច្នេះបន្ទាប់ពីពួកគេញ៉ាំហើយ ពួកគេក៏បានហៅអ្នកបម្រើ ឬក៏អ្នកលក់ ដើម្បីឲ្យមកគិតលុយ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថានៅលើតុគឺអស់ទាំងអស់តែម្ដង គឺអស់ទាំងបាយ អស់ទាំងភេសជ្ជៈ អស់ទាំងទឹកជ្រលក់ ហើយនិងអត់ទាំងសាច់ អត់ទាំងបន្លែនៅលើតុ អញ្ចឹងពួកគេអត់មានអីញ៉ាំទៀតទេ ដូច្នេះពួកគេក៏បានហៅអ្នកលក់ដើម្បីមកគិតលុយ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញអ្នកលក់ដែលពាក់អាវពណ៌ប្រផេះដៃខ្លី ហើយពាក់អាវអៀមពណ៌សនោះផងដែរ គាត់ពាក់អៀមពណ៌ស គាត់កំពុងតែកាន់ក្រដាសមួយ ឬក៏កូនសៀវភៅតូចមួយ ដើម្បីគិតលុយ ដែលគាត់គិតរាប់បញ្ចូលទាំងសាច់ ទាំងបន្លែ ទាំងទឹកស៊ុប ទាំងបាយ ហើយនិងទឹកជ្រលក់ ឬក៏ភេសជ្ជៈ ដែលពួកគេបានយកមកញ៉ាំទាំងអស់ គឺគិតបញ្ចូលគ្នា អញ្ចឹងអ្នកលក់ក៏បានអាននូវអ្វីដែលពួកគេបានញ៉ាំ ប្រាប់ទៅដល់អតិថិជនរបស់គេ ដើម្បីឲ្យពួកគេច្បាស់ថា តើគេគិតលុយត្រឹមត្រូវដែរឬទេ អញ្ចឹងមុននឹងគិតលុយ អ្នកលក់តែងតែអាននូវអ្វីដែលយើងបានញ៉ាំ ដូច្នេះយើងអាចបញ្ជាក់ថា

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

តើអ្នកលក់នោះគិតលុយត្រឹមត្រូវដែរឬទេ។ ជាក់ស្តែងនៅក្នុងរូបភាពនេះ
អ្នកលក់បានអានហើយនូវអ្វីដែលគេញ៉ាំហើយ ក៏បានប្រាប់អំពីតម្លៃនៃសាច់គោឡើងភ្នំ
ដែលគេបានញ៉ាំថាតើអស់ចំនួនប៉ុន្មាន អញ្ចឹងបន្ទាប់ពីអ្នកលក់ប្រាប់អំពីតម្លៃនៃសាច់គោឡើងភ្នំ
ដែលគេញ៉ាំហើយ ឬក៏ប្រាប់ពីតម្លៃនៃមុខម្ហូបដែលគេញ៉ាំរួចរាល់ហើយ
អ្នកទាំងបីក៏បានចេញលុយស្មើៗគ្នា បានន័យថាពួកគេចូលលុយគ្នាដើម្បីញ៉ាំ
អញ្ចឹងការញ៉ាំអាហារពេលល្ងាច ឬក៏អាហារជួបជុំគ្នានៅក្នុងហាង ពេលខ្លះគឺយើងចូលលុយគ្នា
បានន័យថាយើងចេញលុយស្មើៗគ្នា ហើយពេលខ្លះទៀត គឺមានមនុស្សតែម្នាក់ប៉ុណ្ណោះ
ដើម្បីចេញលុយ ប៉ុន្តែនៅក្នុងរូបភាពនេះ ពួកគេជាមិត្តភក្តិនឹងគ្នា ដូច្នេះពួកគេចេញលុយស្មើៗគ្នា
ដែលយើងឃើញម្នាក់ៗកាន់លុយរៀងៗខ្លួន ដោយគេយកចំនួនថ្លៃសរុបរបស់ម្ចាស់ហាង
ដែលគេបានប្រាប់ថាអស់ប៉ុន្មានហើយមកចែកជាបី អញ្ចឹងចែកជាបីយើងឃើញ
យើងអាចដឹងចំនួនថាតើម្នាក់ៗត្រូវចេញលុយចំនួនប៉ុន្មាន។ អញ្ចឹងនៅក្នុងរូបភាពនេះ
ពួកគេក៏បានដឹងអំពីតម្លៃ ហើយពួកគេក៏បានចូលលុយគ្នា ឬក៏ [share] ឬក៏យើងហៅថាចូលលុយគ្នា
ដើម្បីឲ្យបង្គ្រប់ទៅឲ្យអ្នកលក់ អញ្ចឹងពួកគេកាន់លុយរៀងៗខ្លួន ដើម្បីឲ្យទៅអ្នកលក់
ដើម្បីឲ្យថ្លៃអ្វីដែលគេញ៉ាំ ឬក៏ឲ្យថ្លៃសាច់គោឡើងភ្នំដែលគេបានញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ បន្ទាប់ពីពួកគេញ៉ាំបានហើយនិងគិតលុយ
នៅក្នុងហាងរួចរាល់ហើយ ពួកគេក៏ត្រលប់មកផ្ទះវិញ ប៉ុន្តែដោយសារតែពេលនោះជាពេលយប់
អញ្ចឹងនៅពេលដែលពួកគេទៅរៀងល្ងាចហើយ បានន័យថាថ្ងៃរសៀល ដូច្នេះទម្រាំតែគេញ៉ាំចប់
ទម្រាំតែគេនិយាយគ្នាហើយនិងញ៉ាំចប់ គឺវាជាពេលយប់ អញ្ចឹងនៅក្នុងរូបភាពទីដប់មួយនេះ
យើងឃើញមានព្រះចន្ទកំពុងតែរះជាមួយនឹងផ្កាយជាច្រើននៅលើមេឃ ដោយសារតែពេលយប់
អញ្ចឹងអត់មានព្រះអាទិត្យទេ មានតែព្រះចន្ទនិងផ្កាយ អញ្ចឹងពួកគេបានជិះម៉ូតូត្រលប់មកផ្ទះវិញ
ដោយបុរសពាក់អាវខៀវនោះ គាត់ជិះម៉ូតូ ពាក់មួកសុវត្ថិភាព
ហើយឌុបនារីដែលពាក់អាវពណ៌ប្រផេះនោះដដែល ចំណែកឯនារីពាក់អាវលឿង និងស្លៀកខោខ្មៅ
គាត់ជិះម៉ូតូម្នាក់ឯងដដែល ដែលពួកគេជិះម៉ូតូក្បែរគ្នា ដើម្បីការពារគ្នាទៅវិញទៅមក
ក្រែងលោមានគ្រោះថ្នាក់ផ្សេងៗ ពួកគេអាចជួយគ្នាបាន អញ្ចឹងពួកគេអត់ទៅចោលគ្នាទេ
គឺពួកគេជិះក្បែរគ្នា ឬក៏ជិះទន្ទឹមគ្នា ដើម្បីនិយាយគ្នាលេងផង និងដើម្បីការពារគ្នាផង
ហើយដោយសារតែពេលនោះជាពេលយប់ ដូច្នេះពួកគេទាំងពីរគឺត្រូវតែជិះម៉ូតូបើកភ្លើង
អញ្ចឹងយើងឃើញពេលយប់ គឺយើងឃើញមានភ្លើងម៉ូតូបើក អញ្ចឹងបានន័យថាពួកគេទាំងពីរនាក់
បើកភ្លើងម៉ូតូដើម្បីបំភ្លឺផ្លូវ ដោយសារតែពេលយប់គឺងងឹត ដូច្នេះយើងអត់អាចមើលឃើញនោះទេ
អញ្ចឹងដើម្បីមើលឃើញបាន យើងត្រូវតែបើកភ្លើងម៉ូតូ ដើម្បីបំភ្លឺផ្លូវ
ដើម្បីឲ្យយើងជិះទៅមានសុវត្ថិភាព ព្រោះថាពេលខ្លះប្រសិនបើយើងអត់បើកភ្លើង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ជិះនៅទីកន្លែងងងឹត ប្រសិនបើផ្លូវនោះមានក្រឡុក ឬក៏ផ្លូវនោះមានឧបសគ្គនានា
យើងអត់អាចមើលឃើញនោះទេ ដូច្នេះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ ដួលម៉ូតូ ឬក៏ផុងម៉ូតូ
ជាប់ម៉ូតូជាដើម អញ្ចឹងយើងត្រូវបើកភ្លើង ដើម្បីមើលផ្លូវឲ្យបានច្បាស់មុននឹងយើងជិះ
ដើម្បីឲ្យរក្សាសុវត្ថិភាពរបស់យើងឲ្យបានល្អ អញ្ចឹងនៅក្នុងរូបភាពទី ១១ នេះ
គឺពួកគេត្រលប់ពីហាងលក់សាច់គោឡើងភ្នំវិញត្រលប់ទៅផ្ទះ
បន្ទាប់ពីពួកគេបានញ៉ាំសាច់គោឡើងភ្នំជាមួយគ្នានៅក្នុងថ្ងៃចុងសប្តាហ៍រួចរាល់ហើយ
ដូច្នេះពួកគេត្រលប់ទៅវិញនៅពេលយប់ អញ្ចឹងនៅពេលយប់ គឺតែងតែមានមេឃងងឹត
ដូច្នេះពួកគេត្រូវជិះម៉ូតូទៅផ្ទះវិញដោយបើកភ្លើង។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.